№ 37
08-10-97

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៥ លេខ ៣៧ ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ១៩៩៧

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសម្រេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

មាតិកា

I-រាជរដ្ឋាភិបាល

១-អនុក្រឹត្យ

៦-១០-១៩៩៧	-អនុក្រឹត្យលេខ ៥៩ អនក្រ.បក ស្តីពីការអនុវត្តន៍របបសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា	២១៤៩
៨.១០.១៩៩៧	-អនុក្រឹត្យលេខ ៦០ អនក្រ.បក ស្តីពីការបង្កើតស្នងការដ្ឋានពិសេសការពារបេតិកភ័ណ្ឌ	២១៥៥

II-ការងារបណ្តាក្រសួង

១-ទីស្តីការគណៈរដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ

ប្រកាស

០៦.១០.១៩៩៧	-ប្រកាសលេខ ២៦៣/៩៧ ពម.ប្រក ស្តីពីការតែងតាំង មន្ត្រីរាជការ	២១៥៩
០៦.១០.១៩៩៧	-ប្រកាសលេខ ២៦៤/៩៧ ពម.ប្រក ស្តីពីការតែងតាំង មន្ត្រីរាជការ	២១៦០
០៧.១០.១៩៩៧	-ប្រកាសលេខ ២៦៥/៩៧ ពម.ប្រក ស្តីពីការតែងតាំង មន្ត្រីរាជការ	២១៦២
០៧.១០.១៩៩៧	-ប្រកាសលេខ ២៦៦/៩៧ ពម.ប្រក ស្តីពីការតែងតាំង មន្ត្រីរាជការ	២១៦៣

២-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សេចក្តីសំរេច

០៧.១០.១៩៩៧	-សេចក្តីសំរេចលេខ ៥៥៤ សសរ.មសក្រខ ស្តីពីការបែងចែកនិស្សិតចំនួន ១៤ នាក់ ដែលទើបបញ្ចប់ការសិក្សាពីបរទេស	២១៦៤

I រាជរដ្ឋាភិបាល

អនុក្រឹត្យ

អនុក្រឹត្យលេខ ៥៩ អនក្រ.បក

ស្តីពី

ការអនុវត្តន៍របបសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

*****

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី១០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួល សមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួល សមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦ នស. ៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
- បានឃើញព្រះរាជក្រមលេខ នស.រកម ០១៩៦/១៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត ០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួល សមាសភាពរាជរដ្ឋាភិបាល

-តាមសេចក្តីស្នើសុំពីរដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន

-បានការយល់ព្រមពីគណៈរដ្ឋមន្ត្រី នាសម័យប្រជុំ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ១៩៩៧

សំរេច

ជំពូកទី ១

របបសោធននិវត្តន៍

មាត្រា ១ : អ្នករាជការទាំងពីរភេទ ត្រូវបានទទួលរបបសោធននិវត្តន៍ ប្រចាំខែបាន លុះត្រាតែបានបំពេញតាមល័ក្ខខ័ណ្ឌ ដូចមានចែងក្នុងមាត្រា៩៤ និងមាត្រា៩៥ នៃច្បាប់ស្តីពីសហលក្ខិកៈមន្ត្រីរាជការស៊ីវិល ។

មាត្រា ២ : អ្នករាជការទាំងពីរភេទ ត្រូវបានទទួលប្រាក់សោធននិវត្តន៍អតីតភាព ស្មើនឹង៨០ភាគរយ នៃបៀវត្សសុទ្ធសាធនរបស់សាមីខ្លួន លុះត្រាតែបានបំពេញការងារយ៉ាងតិច៣០ឆ្នាំ ។

ប្រាក់សោធនអតីតភាពនេះ ត្រូវបានអនុវត្តតាមករណីដូចខាងក្រោម :-

-អ្នករាជការមានអាយុ៥៥ ឆ្នាំយ៉ាងតិច និងមានអតីតភាពការងារ ៣០ឆ្នាំយ៉ាងតិច ។

-អ្នករាជការដែលមានអតីតភាពការងារ៣០ឆ្នាំឡើងទៅ ហើយបានស្ម័គ្រចិត្តសុំចូលនិវត្តន៍មុនអាយុ៥៥ឆ្នាំ ។

មាត្រា ៣ : ចំពោះអ្នករាជការ ដែលបានបំពេញល័ក្ខខ័ណ្ឌចូលនិវត្តន៍ ដូចមានចែងក្នុងមាត្រា១ខាងលើ ហើយមានអតីតភាពការងារ២០ឆ្នាំយ៉ាងតិច ត្រូវបានទទួលប្រាក់សោធននិវត្តន៍ អប្បបរិមាស្មើនឹង៦០ភាគរយនៃបៀវត្សសុទ្ធសាធរបស់សាមីខ្លួន ។ អ្នករាជការដែលបានបំពេញការងារ លើសពី២០ឆ្នាំឡើងត្រូវបានទទួលប្រាក់សមាមាត្របន្ថែម២ភាគរយ ក្នុង១ឆ្នាំលើបៀវត្សសុទ្ធសាធរបស់សាមីខ្លួន។

ប្រាក់សោធននិវត្តន៍សមាមាត្រនេះ ត្រូវបានគិតតាមករណីពីរយ៉ាងដូចខាងក្រោម :-

១-មិនត្រូវខ្ពស់ជាងប្រាក់សោធននិវត្តន៍អតីតភាព៨០ភាគរយឡើយ ។

២-មិនត្រូវទាបជាងប្រាក់បៀវត្ស អប្បបរិមាសុទ្ធសាធប្រចាំខែ នៃតារាងគំប្រាក់របស់សាមីខ្លួនឡើយ។

មាត្រា ៤ : ប្រាក់សោធននិវត្តន៍ ប្រចាំខែរបស់និវត្តជនម្នាក់ៗ ត្រូវបានគិតបន្ថែមប្រាក់តំបន់នៅតាមតំបន់ដែលសាមីខ្លួនរស់នៅ ប្រាក់ប៉ះពាល់សុខភាព ចំពោះអ្នករាជការដែលធ្វើការងារធ្ងន់ ការងារ

លំបាក ការងារប៉ះពាល់សុខភាព ដូចពេលកំពុងបំរើការងារមុនពេលចូលនិវត្តន៍ ប្រាក់ឧបត្ថម្ភ ប្រពន្ធ កូន ក្រោមអាយុ១៥ឆ្នាំ និងចាប់ពីអាយុ១៥ឆ្នាំឡើងទៅត្រូវមានលិខិតបញ្ជាក់ការសិក្សាពី ស្ថាប័នមាន សមត្ថកិច្ច និង ប្រាក់ឧបត្ថម្ភផ្សេងៗទៀតដែលរដ្ឋបានកំនត់ ។

មាត្រា ៥ : អ្នករាជការដែលត្រូវបានក្រសួង ស្ថាប័នប្រកាសអោយចូលនិវត្តន៍ ត្រូវបានទទួលប្រាក់ឧបត្ថម្ភ ម្តង គត់ ស្មើនឹងបៀវត្សសរុបប្រចាំខែ ចំនួន ៨ខែ ។

មាត្រា ៦ : អ្នករាជការដែលមានអាយុគ្រប់ចូលនិវត្តន៍ ប៉ុន្តែមានអតីតភាពការងារតិចជាង២០ឆ្នាំ មិនត្រូវផ្តល់ ប្រាក់សោធននិវត្តន៍ឡើយ ។ ក្នុងករណីនេះ រដ្ឋផ្តល់ប្រាក់ឧបត្ថម្ភជាប្រាក់សោធននិវត្តន៍ ដែល បានកាត់ទុកនិងប្រាក់ឧបត្ថម្ភផ្សេងៗទៀត តែមួយលើក ។ ប៉ុន្តែនៅពេលមិនទាន់បានបង្កើត មេឡាសោធននិវត្តន៍ និងបាត់បង់សម្បទាវិជ្ជាជីវៈ រដ្ឋត្រូវចំណាយប្រាក់ឧបត្ថម្ភនេះ ដោយគិត តាមចំនួនឆ្នាំ ដែលសាមីខ្លួនបានបំរើការងាររដ្ឋ ហួតដល់ថ្ងៃដែលត្រូវបញ្ឈប់ពីការងារ ។ ប្រាក់ឧបត្ថម្ភនេះត្រូវគិតតាមចំនួនឆ្នាំ ដែលបានបំរើការងាររដ្ឋ ដោយកំណត់ទាបបំផុត ស្មើនឹង បៀវត្សសរុបប្រចាំខែ របស់សាមីខ្លួនគុណនឹង៤ ហើយខ្ពស់បំផុតស្មើនឹងបៀវត្ស សរុបប្រចាំខែ របស់សាមីខ្លួន គុណនឹង ១០ ។

មាត្រា ៧ : ចំពោះអ្នករាជការ ដែលដល់អាយុចូលនិវត្តន៍ និងមានអតីតភាពការងារគ្រប់ ៣០ ឆ្នាំ ដូចមាន ចែងក្នុងមាត្រា ៥៦ នៃច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ហើយត្រូវបានរដ្ឋអនុញ្ញាត អោយ បន្តការងារបន្ថែមទៀត មិនត្រូវកាត់ទុកប្រាក់សោធននិវត្តន៍ទៀតឡើយ ។

មាត្រា ៨ : របៀបគិតអតីតភាពការងាររបស់អ្នករាជការ ត្រូវបានកំណត់ដូចខាងក្រោម :-

រយៈពេលបំរើការងាររួម នៃអ្នករាជការស៊ីវិល គឺជារយៈពេលបំរើការងាររដ្ឋគ្រប់របបសង្គម ដោយឡែក ចំពោះអ្នករាជការដែលធ្លាប់បានបំរើការងាររដ្ឋមុន ឆ្នាំ១៩៧៥ ហើយពុំបានបំរើ ការងារក្នុងរបប ប៉ុល ពត ក៏ត្រូវបានគិតបន្ថែមរយៈពេលបំរើការងារ ០៣ឆ្នាំ ០៨ខែ និង ២០ថ្ងៃ ថែមទៀតដែរ ។

រយៈពេលបំរើការងារ នៃអ្នករាជការស៊ីវិលរួមមាន :-

-រយៈពេលបំរើការងារ ក្នុងក្របខ័ណ្ឌពេញសិទ្ធិ នៅតាមក្រសួង ស្ថាប័ននានារបស់រដ្ឋ

-រយៈពេលធ្វើកម្មសិក្សា ឬ បណ្តុះបណ្តាលមុខវិជ្ជាជីវៈ ក្នុង ឬ ក្រៅប្រទេសរបស់អ្នករាជការក្នុងក្របខ័ណ្ឌរដ្ឋ ។

-រយៈពេលដែលរដ្ឋចាត់អោយទៅបំរើការងារ នៅក្រៅប្រទេស

-រយៈពេលឃាត់ ឬ ឃុំខ្លួន តែក្រោយមករកកំហុសពុំឃើញ

-រយៈពេលបំរើការងារ ក្នុងកងយោធពលខេមរភូមិន្ទ និង នគរបាលជាតិ

-រយៈពេលធ្វើកម្មសិក្សា មុនបញ្ចូលក្របខ័ណ្ឌពេញសិទ្ធិ

មិនត្រូវចាត់ទុកជារយៈពេលបំរើការងារ គឺរយៈពេលត្រូវបានអនុញ្ញាតអោយឈប់ទំនេរ ដោយមិនទទួលបៀវត្ស ។

មាត្រា ៩ : អ្នករាជការស៊ីវិលទាំងពីរភេទ ដែលមានអាយុលើសពី៥៥ឆ្នាំ អាចបន្តការងារបានលុះត្រាតែបានបំពេញលក្ខខ័ណ្ឌ ក្នុងមាត្រា៦៣ នៃច្បាប់សហលក្ខិកៈមន្ត្រីរាជការស៊ីវិល និងអនុក្រឹត្យលេខ៨០អនក្របក ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ១៩៩៦ ស្តីពីការកំណត់លក្ខណៈវិនិច្ឆ័យមន្ត្រីរាជការស៊ីវិល ដែលស្នើសុំពន្យារពេលចូលនិវត្តន៍ ។

មាត្រា ១០ : នៅពេលនិវត្តជនទទួលមរណៈភាព គ្រួសារនៃសពត្រូវបានរដ្ឋ ផ្តល់ប្រាក់ឧបត្ថម្ភមួយលើកចំនួន ១២ខែ លើប្រាក់សោធននិវត្តន៍សរុប ប្រចាំខែរបស់សាមីខ្លួន ដើម្បីធ្វើបុណ្យតាមប្រពៃណី ។ ដោយឡែក ចំពោះសហព័ន្ធនៃសពត្រូវបានបន្តទទួលប្រាក់ឧបត្ថម្ភប្រចាំខែ រហូតដល់ពេលគាត់ស្លាប់ ឬ មានគ្រួសារថ្មី ។ កូនកំព្រានៃសពត្រូវបានទទួលប្រាក់ឧបត្ថម្ភប្រចាំខែ ដូចកូនកំព្រានៃសពមន្ត្រីរាជការ រហូតដល់អាយុ ១៥ ឆ្នាំ និងចាប់ពីអាយុ ១៥ ឆ្នាំឡើងទៅ ត្រូវមានលិខិតបញ្ជាក់ការសិក្សាពីស្ថាប័នមានសមត្ថកិច្ច ។

ជំពូកទី ២

របបសោធនបាត់បង់សម្បទាវិជ្ជាជីវៈ

មាត្រា ១១ : អ្នករាជការទាំពីរភេទ ដែលបាត់បង់សម្បទាវិជ្ជាជីវៈ ហើយមានអតីតភាពការងារចាប់ពី ២០ ឆ្នាំ ទៅដល់ក្រោម ៣០ ឆ្នាំ ហើយពុំគ្រប់អាយុចូលនិវត្តន៍ មានសិទ្ធិទទួលប្រាក់សោធនបាត់បង់

សម្បទាវិជ្ជាជីវៈ ដូចមានចែងក្នុងមាត្រា ១៩ នៃច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។ ក្នុងករណីមិនគ្រប់លក្ខខ័ណ្ឌនេះ ត្រូវបានបញ្ឈប់ពីការងារនៅពេលណាក៏បាន ហើយត្រូវទទួលប្រាក់ឧបត្ថម្ភ និង ប្រាក់កាត់ទុកតែម្តងគត់ ដូចអ្នករាជការពុំគ្រប់លក្ខខ័ណ្ឌចូលនិវត្តន៍ដែរ ។

ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈ អតិបរិមាត្រូវបានកំណត់ ៦៥ ភាគរយ នៃបៀវត្សសុទ្ធសាធ ប្រាក់សោធននេះត្រូវអនុវត្តចំពោះអ្នករាជការណា ដែលបាត់បង់ សម្បទាវិជ្ជាជីវៈ ដោយគ្រោះថ្នាក់ ការងារ និង បំពេញបេសកកម្ម ។

ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈ អប្បបរិមាត្រូវបានកំណត់ ៥០ ភាគរយ នៃបៀវត្សសុទ្ធសាធ ប្រាក់សោធននេះ ត្រូវអនុវត្តចំពោះអ្នករាជការណា ដែលបាត់បង់ សម្បទាវិជ្ជាជីវៈ ដោយជំងឺ ឬ គ្រោះ ថ្នាក់ផ្សេង ៗ ។ ចំពោះអ្នករាជការ ដែលមានអតីតភាពការងារលើសពី ២០ ឆ្នាំឡើងទៅ ត្រូវបានទទួលប្រាក់ សោធនបាត់បង់សម្បទាវិជ្ជាជីវៈអប្បបរិមា និងត្រូវបានទទួលប្រាក់សមាមាត្របន្ថែម ១.៥ ភាគរយ ក្នុងមួយឆ្នាំលើបៀវត្ស សុទ្ធសាធរបស់សាមីខ្លួន ។ ប៉ុន្តែប្រាក់សោធនសមាមាត្រនេះ មិនត្រូវលើសប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈ អតិបរិមា ឬ មិនត្រូវទាបជាង ៥០ ភាគរយនៃប្រាក់បៀវត្ស អប្បបរិមាសុទ្ធសាធ នៃតារាងកាំប្រាក់របស់សាមី ខ្លួនឡើយ ។

ការកំណត់ថា បាត់បង់សម្បទាវិជ្ជាជីវៈ នៃអ្នករាជការស៊ីវិល ត្រូវសំរេចដោយគណៈកម្មការមួយ ដូចមានចែងក្នុងមាត្រា ១៩ នៃច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

មាត្រា ១២ : អ្នករាជការបាត់បង់សម្បទាវិជ្ជាជីវៈម្នាក់ ៗត្រូវបានទទួលប្រាក់ឧបត្ថម្ភ ប្រាក់តំបន់ ប្រាក់ប៉ះពាល់សុខភាព ប្រាក់ឧបត្ថម្ភប្រពន្ធ កូន និងប្រាក់ឧបត្ថម្ភផ្សេង ៗទៀត ដូចជានិវត្តជនដែរ ។

មាត្រា ១៣ : អ្នករាជការដែលបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវបានអនុវត្តរបៀបគិតរយៈពេលបំពេញការងារ ដូចជានិវត្តជនដែរ ។

មាត្រា ១៤ : អ្នរាជការដែលក្រសួង ស្ថាប័ន តម្រូវអោយចូលបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវបានទទួលប្រាក់ឧបត្ថម្ភម្តងគត់ ស្មើនឹងបៀវត្សសរុបប្រចាំខែចំនួន ៧ ខែ ។

ក

មាត្រា ១៥ : អ្នករាជការដែលបាត់បង់សម្បទាវិជ្ជាជីវៈ នៅពេលទទួលមរណភាព គ្រួសារនៃសពត្រូវបាន វជ្ជ ឧបត្ថម្ភប្រាក់ ដូចជានិវត្តជនដែរ ។

ជំពូកទី ៣
ភារកិច្ច និង សមត្ថកិច្ច នៃការគ្រប់គ្រង
បើកប្រាក់សោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ

មាត្រា ១៦ : ជារៀងរាល់ឆ្នាំ ក្រសួង ស្ថាប័ន នីមួយៗ ត្រូវលើកគំរោងផែនការស្ថិតិ និង ថវិកាសំរាប់អ្នករាជការក្រោមឱវាទ ដែលគ្រប់ល័ក្ខខ័ណ្ឌចូលនិវត្តន៍ និង ចូលបាត់បង់សម្បទាវិជ្ជាជីវៈ ជូនក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន និងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីបំរុងថវិកាសំរាប់បើកផ្តល់និវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ ។

ក្រសួង ស្ថាប័ននីមួយៗមានភារកិច្ច លើកគំរោងផែនការថវិកា និង បើកប្រាក់ឧបត្ថម្ភលើកដំបូង ជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ។ ការបើកប្រាក់ ឧបត្ថម្ភលើកដំបូងនេះ ត្រូវស្នើទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ការគ្រប់គ្រង និង ការបើកប្រាក់សោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈប្រចាំខែ ជាសមត្ថកិច្ចរបស់ ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន រហូតដល់ពេលបង្កើតបានបេឡាសោធននិវត្តន៍ និង បាត់បង់សម្បទាវិជ្ជាជីវៈ ។

មាត្រា ១៧ : និវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលបានទទួលប្រាក់សោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈប្រចាំខែកន្លងមក ត្រូវបានគិតបញ្ចូលប្រាក់ឧបត្ថម្ភ ប្រពន្ធ កូន ដូចមានចែងក្នុងមាត្រា ៤ នៃអនុក្រឹត្យនេះ ។

មាត្រា ១៨ : ក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន ត្រូវចេញប្រកាសណែនាំអនុវត្តអនុក្រឹត្យនេះ ។

ជំពូកទី ៤
អវសានប្បញ្ញត្តិ

មាត្រា ១៩ : សហរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង គ្រប់ក្រសួងស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង ៗ ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខា និងត្រា	ហត្ថលេខា និងត្រា
អ៊ឹង ហួត	ហ៊ុន សែន

អនុក្រឹត្យលេខ ៦០ អនក្រ.បក
ស្តីពី
ការបង្កើតស្នងការដ្ឋានពិសេសការពារបេតិកភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី១០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត-១០៩៤-៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួល សមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ជស-រកត-០៨៩៧-១៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែ សំរួល សមាសភាពរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រមលេខ០២ នស.៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀប និង ការប្រព្រឹត្តិ ទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស.រកម-០១៩៦-០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើត ក្រសួងក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រឹត្យលេខ នស-រកត ០២៩៥ ១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរ ដើម្បីការពារតំបន់រមណីយដ្ឋាន និង រៀបចំតំបន់អង្គរហៅថាអាជ្ញាធរ អប្សរា

-បានឃើញព្រះរាជក្រមលេខ នស-រកម-០១៩៦-២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌

-តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

-បានការអនុម័តរបស់គណៈរដ្ឋមន្ត្រី នាសម័យប្រជុំ ថ្ងៃទី២១ ខែសីហា ឆ្នាំ១៩៩៧

សំរេច

មាត្រា ១ : បង្កើតស្នងការដ្ឋានពិសេសការពារបេតិកភ័ណ្ឌដែល មានទីតាំងក្នុងបរិវេណតំបន់អង្គរ នៃខេត្ត សៀមរាប ។ ស្នងការដ្ឋានពិសេសការពារបេតិកភ័ណ្ឌ ស្ថិតនៅក្រោមឱវាទផ្ទាល់របស់ ក្រសួង មហាផ្ទៃ ហើយមានភាតព្វកិច្ចសហការជាមួយអាជ្ញាធរអប្សរា និង អាជ្ញាធរខេត្តសៀមរាប ។

មាត្រា ២ : ស្នងការដ្ឋានពិសេសការពារបេតិកភ័ណ្ឌ មានភារកិច្ច និងសិទ្ធិដូចតទៅ :-

ក-ភារកិច្ច :

១-លើកគំរោងផែនការ និង អនុវត្តវិធានការមុខជំនាញ តាមគោលការណ៍ដឹកនាំ ណែនាំ របស់ ក្រសួងមហាផ្ទៃ ដោយសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរអប្សរា និងអាជ្ញាធរខេត្តសៀមរៀប។

២-ការពារសុវត្ថិភាព សន្តិសុខ និង រក្សារបៀបរៀបរយ សណ្តាប់ធ្នាប់សាធារណៈ ក្នុងភូមិសាស្ត្រ **តំបន់អង្គរ ដែលកំណត់ដោយអាជ្ញាធរអប្សរា ។**

៣-ស្រាវជ្រាវ និង អនុវត្តវិធានការបង្ការទប់ស្កាត់ និង បង្ក្រាបរាល់អំពើល្មើសច្បាប់ ការបំផ្លិច **បំផ្លាញ ការលួច** លាក់ ប្លន់ ការទិញ លក់ ការដឹកជញ្ជូនបេតិកភ័ណ្ឌសម្បត្តិវប្បធម៌ប្រវត្តិសាស្ត្រ **ក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួន ។**

៤-ការពារសុវត្ថិភាព សន្តិសុខភ្ញៀវជាតិ និងភ្ញៀវអន្តរជាតិ ដែលមកបំពេញបេសកកម្ម ធ្វើទស្សន **កិច្ច ឬ ធ្វើទេសចរណ៍**ក្នុងតំបន់អង្គរ ។

៥-ស៊ើបអង្កេតបទឧក្រិដ្ឋ ចាប់ខ្លួន ឃាត់ខ្លួន និង ត្រួតពិនិត្យ ឆែកឆេរ ជនល្មើសដែលពាក់ព័ន្ធ **ក្នុងការបំផ្លិចបំផ្លាញ** ការលួច លាក់ ប្លន់ ការទិញ លក់ ដឹកជញ្ជូនបេតិកភ័ណ្ឌ សម្បត្តិវប្បធម៌ **ប្រវត្តិសាស្ត្រ នៃ តំបន់អង្គរ** កសាងសំណុំរឿង និងបញ្ជូនជនល្មើសជាមួយវត្ថុតាងទៅតុលាការ។

៦-បោះទីតាំងឈរជើងការពារ និង ចល័តយាមល្បាត ឃ្លាំមើលតាមចំណុចសំខាន់ៗ នៃតំបន់អង្គរ។

៧-សហការជាមួយស្នងការដ្ឋាន នគរបាលខេត្តសៀមរាប មេបញ្ជាការយោធភូមិភាគទី៤ មេបញ្ជា **ការតំបន់ប្រតិបត្តិការសឹករងខេត្តសៀមរាប** មេបញ្ជាការកងរាជអាវុធហត្ថខេត្តសៀមរាប អភិ- **រក្សដ្ឋានអង្គរ** មន្ទីរធម្មការ និង កិច្ចការសាសនាខេត្ត មន្ទីរទេសចរណ៍ខេត្ត អង្គភាពគយ **រដ្ឋាករប្រចាំខេត្ត និង** អង្គភាពមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងៗទៀត ដើម្បីអនុវត្តវិធានការ បង្ការ **ទប់ស្កាត់ បង្ក្រាបបទល្មើស** និង ការបង្កគ្រោះមហន្តរាយបំផ្លិចបំផ្លាញដល់បេតិកភ័ណ្ឌ វប្បធម៌ **ប្រវត្តិសាស្ត្រ ។**

៨-តាមរយៈអាជ្ញាធរអប្សរា ធ្វើទំនាក់ទំនងជាមួយអង្គការ **យូណេស្កូ** និង អង្គការអន្តរជាតិនានា **ដើម្បីទទួលការណែនាំ** ផ្សព្វផ្សាយគោលការណ៍ផ្សេងៗ និង ទទួលជំនួយឧបត្ថម្ភបំរើអោយ **ការងារ ការពារបេតិកភ័ណ្ឌវប្បធម៌ ។**

៩-ធ្វើសេចក្តីរាយការណ៍ជាប្រចាំ ឬ ជាបន្ទាន់អំពីសភាពការណ៍ ហេតុការណ៍ផ្សេងៗ ដែលពាក់ព័ន្ធ **ដល់ការអនុវត្តន៍ភារកិច្ច** ក្នុងសមត្ថកិច្ចជំនាញរបស់ខ្លួនមកក្រសួងមហាផ្ទៃ និង អាជ្ញាធរអប្សរា **និង ចម្លងជូនអាជ្ញាធរខេត្ត ។**

១០-ធ្វើបញ្ជីគ្រប់គ្រងចលនទ្រព្យ និង អចលនទ្រព្យ របស់ស្នងការពិសេសការពារបេតិកភ័ណ្ឌ តាម **ការកំណត់របស់ក្រសួងមហាផ្ទៃ** និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

១១-ធ្វើការងាររដ្ឋបាល បុគ្គលិក ភស្តុភារ គណនេយ្យ និង ថវិកា តាមការកំណត់របស់ក្រសួងមហាផ្ទៃ និង អាជ្ញាធរអប្សរា ។

១២-អនុវត្តបទបញ្ជា និង ភារកិច្ចផ្សេងៗទៀត ដែលក្រសួងមហាផ្ទៃ និង អាជ្ញាធរអប្សរាប្រគល់អោយ។

ខ-សិទ្ធិ :

១-ទាមទារជាប្រចាំនូវបញ្ជីសារពើភ័ណ្ឌ បេតិកភ័ណ្ឌវប្បធម៌ប្រវត្តិសាស្ត្រ ពីអាជ្ញាធរអប្សរា ។

២-រៀបរៀងសំណើគោលការណ៍ជូនក្រសួងមហាផ្ទៃ និង/ឬ អាជ្ញាធរអប្សរា ដើម្បីចេញបទបញ្ជា និងចាត់វិធានការបង្ការ ទប់ស្កាត់បទល្មើស បង្ក្រោះថ្នាក់មហន្តរាយ បំផ្លិចបំផ្លាញ ព្រមទាំងស្នើអោយ មន្ទីរនានាជុំវិញខេត្ត ផ្តល់របាយការណ៍ពត៌មាន និងឯកសារពាក់ព័ន្ធដល់ការការពារបេតិកភ័ណ្ឌ សម្បត្តិវប្បធម៌ប្រវត្តិសាស្ត្រ ។

៣-គ្រប់គ្រងដឹកនាំ បញ្ជាកងកម្លាំងនគរបាលជាតិ ចំណុះស្នងការពិសេសការពារបេតិកភ័ណ្ឌ ដើម្បីធានាដល់ការអនុវត្តន៍គោលការណ៍បទបញ្ជា របស់ក្រសួងមហាផ្ទៃ និង អាជ្ញាធរអប្សរា ។

៤-អនុញ្ញាតច្បាប់សំរាក ដាក់ពិន្ទុ និងមូលវិចារ ស្នើសរសើរ ស្នើតែងតាំងមុខតំណែង បំពាក់ឋានន្តរសក្តិ ផ្ទេរភារកិច្ច ដាក់វិន័យ ដកហូតមុខតំណែង និង ឋានន្តរសក្តិនាយនគរបាល នាយនគរបាលរង និង ពលនគរបាលចំណុះស្នងការដ្ឋានពិសេសការពារបេតិកភ័ណ្ឌ តាមការកំណត់ របស់ក្រសួងមហាផ្ទៃ ។

៥-អនុវត្តសិទ្ធិផ្សេងៗទៀត ដែលក្រសួងមហាផ្ទៃ និង អាជ្ញាធរអប្សរា ប្រគល់អោយ ។

មាត្រា ៣ : ស្នងការដ្ឋានពិសេសការពារបេតិកភ័ណ្ឌ ថ្នាក់ស្មើស្នងការដ្ឋាននគរបាលខេត្ត ដឹកនាំដោយស្នងការមួយរូប និង មានស្នងការរង ជាជំនួយការ ។

មាត្រា ៤ : ការរៀបចំជាក់ស្តែង នូវភារកិច្ច សិទ្ធិ រចនាសម្ព័ន្ធ និង ក្របខ័ណ្ឌរបស់ស្នងការដ្ឋានពិសេសការពារបេតិកភ័ណ្ឌ ត្រូវកំណត់ដោយប្រកាសក្រសួងមហាផ្ទៃ ។

មាត្រា ៥ : បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាជ្ញាធរអប្សរា អភិបាលខេត្តសៀមរាប និង ប្រធានស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី០៨ ខែតុលា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខា និងត្រា	ហត្ថលេខា និងត្រា
អ៊ឹង ហួត	ហ៊ុន សែន

II-ការចេញបណ្តាក្រសួង

១-ទីស្តីការរដ្ឋមន្ត្រីក្រសួងព័ត៌មាន

ប្រកាស

រាជធានីភ្នំពេញ.ថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៩៧

ប្រកាស លេខ ២៦៣ ព.ម.ប្រក

ស្តីពីការតែងតាំងមន្ត្រីរាជការ

*****

រដ្ឋមន្ត្រីក្រសួងពត៌មាន

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១-១១-៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ន.ស-៩៤ ចុះថ្ងៃទី ២០-៧-៩៤ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ។

-បានឃើញព្រះរាជក្រម ន.ស-រកម-០១៩៦-១៤ ចុះថ្ងៃទី ២៤-០១-៩៦ ស្ដីពីការបង្កើត ក្រសួងពត៌មាន

-យោងលិខិតលេខ ៣៩ លខស ចុះថ្ងៃទី ២៧-៦-៩៧ របស់អភិបាលខេត្តកំពត

-ពិនិត្យលើលក្ខណៈសម្បត្តិ និងសមត្ថភាពមន្ត្រីរាជការ

សំរេច

ប្រការ ១ : តែងតាំងលោក រស់ រ៉ៃ ជាប្រធានមន្ទីរពត៌មានខេត្តកំពត ។

ប្រការ ២ : ឯកឧត្តម អគ្គនាយករដ្ឋបាល-ហិរញ្ញវត្ថុ លោកនាយកខុទ្ទកាល័យ បណ្ណាអគ្គនាយកដ្ឋានចំណុះ លោកប្រធាននាយកដ្ឋានបុគ្គលិក លោកប្រធាននាយកដ្ឋានផែនការគណនេយ្យ-ហិរញ្ញកិច្ច គ្រប់មន្ទីរពត៌មានខេត្ត-ក្រុង និងសាមីខ្លួន ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

ខៀវ កាញារីទ្ធ

==============

រាជធានីភ្នំពេញ.ចុះថ្ងៃទី ០៦ ខែតុលា ឆ្នាំ១៩៩៧

ប្រកាស លេខ ២៦៤ ព.ម.ប្រក

ចុះថ្ងៃទី ០៦ ខែតុលា ឆ្នាំ១៩៩៧

ស្ដីពីការតែងតាំងមន្ត្រីរាជការ

*****

រដ្ឋមន្ត្រីក្រសួងព័ត៌មាន

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១-១១-៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ន.ស-៩៤ ចុះថ្ងៃទី ២០-៧-៩៤ ស្តីពីការរៀបចំ និងការ ប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ។

-បានឃើញព្រះរាជក្រមន.ស-រកម-០១៩៦-១៤ ចុះថ្ងៃទី២៤-០១-៩៦ ស្តីពីការបង្កើតក្រសួង ព័ត៌មាន ។

-យោងចំណាងឯកភាពលេខ ០៣៦១ សរសេណ ចុះថ្ងៃទី ២៥-៨-៩៧ របស់អភិបាលខេត្ត កំពង់ស្ពឺ ។

-ពិនិត្យលើលក្ខណៈសម្បត្តិ និងសមត្ថភាពមន្ត្រីរាជការ

សំរេច

ប្រការ ១ : តែងតាំងថ្នាក់ដឹកនាំមន្ទីរព័ត៌មានខេត្តកំពង់ស្ពឺ ដូចមានរាយនាមខាងក្រោម :

១-លោក សំ ពិសី ជាប្រធានមន្ទីរព័ត៌មានខេត្តកំពង់ស្ពឺ

២-លោក ញ៉ែម ឆ្នំ ជាអនុប្រធានមន្ទីរព័ត៌មានខេត្តកំពង់ស្ពឺ

៣-លោក នី ឌុន្នី ជាអនុប្រធានមន្ទីរព័ត៌មានខេត្តកំពង់ស្ពឺ

ប្រការ ២ : ឯកឧត្តម អគ្គនាយករដ្ឋបាល-ហិរញ្ញវត្ថុ លោកនាយកខុទ្ទកាល័យ បណ្តាអគ្គនាយកដ្ឋានចំណុះ លោកប្រធាននាយកដ្ឋានបុគ្គលិក លោកប្រធាននាយកដ្ឋានផែនការគណនេយ្យ-ហិរញ្ញកិច្ច គ្រប់មន្ទីរព័ត៌មានខេត្ត-ក្រុង និងសាមីខ្លួន ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

ខៀវ កាញារីទ្ធ

=============

រាជធានីភ្នំពេញ.ថ្ងៃទី ០៦ ខែតុលា ឆ្នាំ១៩៩៧

ប្រកាស លេខ ២៦៥ ព.ម.ប្រក
ស្តីពីការតែងតាំងមន្ត្រីរាជការ

* * * * *

រដ្ឋមន្ត្រីក្រសួងពត៌មាន

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ន.ស-៩៤ ចុះថ្ងៃទី ២០-៧-៩៤ ស្តីពីការរៀបចំ និងការ ប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ។

-បានឃើញព្រះរាជក្រមន.ស-រកម-០១៩៦-១៤ ចុះថ្ងៃទី២៤-០១-៩៦ ស្តីពីការបង្កើតក្រសួង ពត៌មាន ។

-យោងតាមតម្រូវការចាំបាច់

-ពិនិត្យលើលក្ខណៈសម្បត្តិ និងសមត្ថភាពមន្ត្រីរាជការ

សំរេច

ប្រការ ១ : តែងតាំងមន្ត្រីរាជការចំនួន ០៨ នាក់ ជាថ្នាក់ប្រធាន និងអនុប្រធានការិយាល័យនាយកដ្ឋានផែនការគណនេយ្យហិរញ្ញកិច្ច នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងពត៌មាន ដូចមានរាយនាមខាងក្រោមនេះ :

ក-ថ្នាក់ប្រធានការិយាល័យ

១-លោក អ៊ុក ឆាវ ជាប្រធាន ការិយាល័យផែនការហិរញ្ញកិច្ច

២-លោក សន់ ហ៊ឿរ ជាប្រធាន ការិយាល័យគណនេយ្យ

៣-លោកស្រី ទីម ម៉ុំ ជាប្រធាន ការិយាល័យចំណូលអាជីវកម្ម

ខ-ថ្នាក់អនុប្រធានការិយាល័យ

១-លោក អ៊ុយ ឃាង ជាអនុប្រធាន ការិយាល័យផែនការហិរញ្ញកិច្ច

២-លោក នួន ដំអាត ជាអនុប្រធាន ការិយាល័យគណនេយ្យ

៣-លោក ស៊ីម ប៊ិច ជាអនុប្រធាន ការិយាល័យគណនេយ្យ

៤-លោក អ៊ិត ថាវធី ជាអនុប្រធាន ការិយាល័យគណនេយ្យ

៥-លោក អាន រ៉េម ជាអនុប្រធាន ការិយាល័យចំណូលអាជីវកម្ម

ប្រការ ២ : ឯកឧត្តម អគ្គនាយករដ្ឋបាល-ហិរញ្ញវត្ថុ លោកនាយកខុទ្ទកាល័យ គ្រប់អគ្គនាយកដ្ឋាន ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការគណនេយ្យ-ហិរញ្ញវត្ថុ និងសាមីខ្លួនក្នុងប្រការ១ ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

ខៀវ កាញារីទ្ធ

================

រាជធានីភ្នំពេញ.ថ្ងៃទី ០៧ ខែតុលា ឆ្នាំ១៩៩៧

ប្រកាស លេខ ២៦៦ ព.ម.ប្រក

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * * * *

រដ្ឋមន្ត្រីក្រសួងពត៌មាន

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១-១១-៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២-នស-៩៤ ចុះថ្ងៃទី ២០-៧-៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ។

-បានឃើញព្រះរាជក្រម នស-រកម-០១៩៦-១៤ ចុះថ្ងៃទី ២៤-០១-៩៦ ស្តីពីការបង្កើត ក្រសួងពត៌មាន

-យោងតម្រូវការចាំបាច់របស់នាយកដ្ឋានបុគ្គលិក

-ពិនិត្យលើលក្ខណៈសម្បត្តិ និងសមត្ថភាពមន្ត្រីរាជការ

សំរេច

ប្រការ ១ : តែងតាំងថ្នាក់អនុប្រធាននាយកដ្ឋានបុគ្គលិកចំនួន ២រូប ដូចមានរាយនាមខាងក្រោម :

១-លោក យឿន ន៉ាំ ជាអនុប្រធាននាយកដ្ឋាន ទទួលបន្ទុកខេត្ត-ក្រុង

២-លោក សែត គីមថា ជាអនុប្រធាននាយកដ្ឋាន ទទួលបន្ទុកកិច្ចការសង្គម

ប្រការ ២ : ឯកឧត្តម អគ្គនាយករដ្ឋបាល-ហិរញ្ញវត្ថុ លោកនាយកខុទ្ទកាល័យ បណ្តាអគ្គនាយកដ្ឋានចំណុះ លោកប្រធាននាយកដ្ឋានបុគ្គលិក លោកប្រធាននាយកដ្ឋានផែនការគណនេយ្យ-ហិរញ្ញកិច្ច និងសាមីខ្លួន ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

ខៀវ កាញារីទ្ធ

===============

២-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សេចក្តីសំរេច

រាជធានីភ្នំពេញថ្ងៃទី ០៧ ខែតុលា ឆ្នាំ១៩៩៧

សេចក្តីសំរេចលេខ ៥៥៤ សសរ.មស.ក្រខ

ស្តីពីការបែងចែកនិស្សិតចំនួន ១៤ នាក់

តែងតាំងនិស្សិតបញ្ចប់ការសិក្សាពីបរទេស

*****

រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។

-បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ។

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៨៣ ថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាព រាជរដ្ឋាភិបាលកម្ពុជា ។

-បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ បក ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

-បានឃើញព្រះរាជក្រឹត្យលេខ ជស រកត ០៨៩៧ ១៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា ។

-យោងលិខិតលេខ ៣១៩ សជណ.អវ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៩៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

សំរេច

ប្រការ ១ : អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ១៤ នាក់ ដែលបានបញ្ចប់ការសិក្សាពីបរទេស ត្រូវបានបែងចែកអោយទៅបំរើការងារ នៅក្រសួងស្ថាប័នមួយចំនួន ដូចមានក្នុងតារាងឧបសម្ព័ន្ធ នៃសេចក្តីសំរេចនេះ ។

ប្រការ ២ : ក្រសួងស្ថាប័នដែលពាក់ព័ន្ធមានភារៈកិច្ចទទួលយកអ្នកបច្ចេកទេសទាំងនេះ ដើម្បីរៀបចំការងារអោយត្រូវតាមមុខជំនាញ និង ផ្តល់បៀវត្សជូនសាមីជន ចាប់ពីថ្ងៃដែលបានចូលបំរើការងារជាផ្លូវការ ។

ប្រការ ៣ : សេចក្តីសំរេចនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

ប្រាក់ សុខ

============

តារាងឧបសម្ព័ន្ធនៃសេចក្តីសម្រេចលេខ ៥៥៤ សសរ មស.គ្រខ ចុះថ្ងៃទី ០៧-១០-៩៧

ស្តីពីការបែងចែកនិស្សិតចំនួន ១៤ នាក់ ដែលបានបញ្ចប់ការសិក្សាពីបរទេស

ល.រ	នាម-គោត្តនាម និងនាមខ្លួន	ភេទ	ថ្ងៃ ខែ ឆ្នាំ កំណើត	អត្តភាពដើម	មុខជំនាញបច្ចេកទេស	កំរិតបណ្តុះបណ្តាល	ប្រទេសបណ្តុះបណ្តាល	កំរិតរបៀបគុណ	អត្តភាពចូលបំរើការងារ
១	អាត សុនិសា	ស្រី	២៨.១០.៧៤	សិស្ស	ភាសាអង់គ្លេសនិងអក្សរសាស្ត្រ	ឧត្តមគរុ	វៀតណាម	៨០ % ខ1១	ក្រសួងអប់រំ យុវជន និងកីឡា
២	ខឹម សុថា	ប្រុស	១០.៩.៧០	សិស្ស	សេដ្ឋកិច្ចនាវាចរណ៍	ឧត្តម	វៀតណាម	៨០ % ខ1១	ក្រសួងសាធារណៈការនិងដឹកជញ្ជូន
៣	វង្ស សុវណ្ណា	ប្រុស	១០.៤.៧០	សិស្ស	សេដ្ឋកិច្ចដឹកជញ្ជូនផ្លូវដែក	ឧត្តម	វៀតណាម	៨០ % ខ1១	ក្រសួងសាធារណការ និងដឹកជញ្ជូន
៤	ស៊ុន វិសាល	ប្រុស	០៤.១២.៧០	សិស្ស	ច្បាប់	ឧត្តម	សូវៀត	៨០ % ខ1១	ក្រសួងយុត្តិធម៌
៥	ហ៊ុ ឡេង	ប្រុស	២០.៤.៧២	សិស្ស	វារីកម្ម	ឧត្តម	សូវៀត	៨០ % ខ1១	ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ
៦	ជា ថាវី	ប្រុស	២១.៣.៧២	សិស្ស	សេដ្ឋកិច្ចកសិកម្ម	ឧត្តម	សូវៀត	៨០ % ខ1១	ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ
៧	សរ ប៊ុនណា	ប្រុស	១០.០១.៧០	សិស្ស	កសិកម្ម	ឧត្តម	សូវៀត	៨០ % ខ1១	ក្រសួងកសិកម្មរុក្ខាប្រមាញ់

									និងនេសាទ
៨	មិក សាផា-ណារា	ប្រុស	០៧.៤.៧៣	សិស្ស	ឱសថសាស្ត្រ	ឧត្តម	សូវៀត	៩០ ½ ខែ	ក្រសួងសុខាភិបាល
៩	ជា ស្រួយ	ប្រុស	០៥.៩.៧១	សិស្ស	នេសាទ ឧស្សាហកម្ម	ឧត្តម	សូវៀត	៩០ ½ ខែ	ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ
១០	ស៊ុន សុផានី	ប្រុស	២៨.១២.៦៨	សិស្ស	ផែនដី	ឧត្តម	សូវៀត	៩០ ½ ខែ	ទីស្តីការគណៈរដ្ឋមន្ត្រី
១១	គុយ វិសាល	ប្រុស	០១.១២.៧១	សិស្ស	បើកបរនាវា	ឧត្តម	សូវៀត	៩០ ½ ខែ	ក្រសួងសាធារណៈការនិងដឹកជញ្ជូន
១២	ហេង នាថមុនី	ប្រុស	០១.១១.៧២	សិស្ស	រុក្ខកម្ម	ឧត្តម	សូវៀត	៩០ ½ ខែ	ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ
១៣	មិន មណីរ័ត្ន	ប្រុស	២១.១០.៧៤	សិស្ស	សំណង់ ស៊ីវិល និង ឧស្សាហកម្ម	ឧត្តម	សូវៀត	៩០ ½ ខែ	ក្រសួងមហាផ្ទៃ
១៤	យក់ សំណាង	ប្រុស	២០.៣.៦៧	សិស្ស	សំណង់ ស៊ីវិល និង ឧស្សាហកម្ម	ឧត្តម	សូវៀត	៩០ ½ ខែ	ក្រសួងសាធារណការនិងដឹកជញ្ជូន

បានបញ្ឈប់បញ្ជីនេះត្រឹមចំនួនដប់បួន "១៤" នាក់ប៉ុណ្ណោះ ។

រាជធានីភ្នំពេញ.ថ្ងៃទី ០៧ ខែ ១០ ឆ្នាំ ១៩៩៧

រដ្ឋលេខាធិកា

ហត្ថលេខា និងត្រា

ប្រាក់ សុខ

បោះពុម្ពនៅរោងពុម្ព ទីស្ដីការគណៈរដ្ឋមន្ត្រី
លើកទី១ ចំនួន ៤០០ ច្បាប់

តម្លៃ ២៧៥០ រៀល